**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អគ្គនាយកដ្ឋានពន្ធដារ**

**នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ......៧៣៨........អពដ

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០១២

# សេចក្តីជូនដំណឹង

អគ្គនាយកដ្ឋានពន្ធដារមានកិត្តិយសសូមជម្រាបជូន ឯកឧត្តម លោក លោកស្រី ដែលជាប្រធាន ក្រសួង ស្ថាប័ន អង្គភាពរដ្ឋ និងជាម្ចាស់សហគ្រាសទាំងអស់មេត្តាជ្រាបថា កន្លងមកអគ្គនាយកដ្ឋានពន្ធដារមានត្រាមូលមួយគ្រឿងប្រើប្រាស់ចាប់ពីឆ្នាំ២០០៨រហូតមក ដល់បច្ចុប្បន្ន។ ត្រានោះបានសឹករិចរិលមានសភាពរលុប ហើយនៅពេលបោះត្រាម្តងៗមើលមិនសូវឃើញច្បាស់។

អគ្គនាយកដ្ឋានពន្ធដារបានធ្វើសំណើទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ ដើម្បីសុំផលិតត្រានេះជាថ្មីឡើងវិញ។ ក្រោយពីមានការឯកភាពពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ ត្រានៃអគ្គនាយកដ្ឋានពន្ធដារថ្មីត្រូវបានផលិតរួចរាល់ជាស្ថាពរ។ អគ្គនាយកដ្ឋានពន្ធដារនឹងដាក់ត្រាថ្មីនេះ ឱ្យប្រើប្រាស់ចាប់ពីពេលនេះតទៅ។

អាស្រ័យហេតុនេះ សូម ឯកឧត្តម លោក លោកស្រីទាំងអស់មេត្តាជ្រាបជាព័ត៌មាន និងទទួលស្គាល់តាមការគួរ។

**ប្រតិភូរាជរដ្ឋាភិបាល**

**ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ**

**ស៊ឹម-អៀង**

សូមភ្ជាប់មកជាមួយនូវគំរូត្រាដែលត្រូវប្រើប្រាស់ថ្មី:

គំរូត្រាចាស់



គំរូត្រាថ្មី

